ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
No. ០៩៧ MOC / SM 2007

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៧

(២)

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកែសម្រួល និងការកំណត់ថ្មីកំរៃគ្រប់គ្រងការនាំចេញ (Export Management Fee)

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
### និង ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តតាមអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វ័យត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- យោងប្រកាសលេខ ២៨៥ ព.ណ. បអពប្រក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការកំណត់កំរៃគ្រប់គ្រងការនាំចេញ
- អនុវត្តតាមប្រកាសលេខ ០០៤ សហវ. មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តនីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមសារាចរណែនាំលេខ ០០២ សហវ.ម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីរជ្ជទេយ្យចំណូល
- អនុវត្តតាមសារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៤ ស្តីពីការកែលំអនិតិវិធីអនុវត្តថវិកា
- យោងសេចក្តីជូនដំណឹងលេខ ៦៨២.សជណ ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០០៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីការបញ្ចុះកំរៃគ្រប់គ្រងការនាំចេញលើផលិតផលទោចក្រយាន និង ការកំណត់កំរៃគ្រប់គ្រងការនាំចេញលើផលិតផលប៊ូឡុង

Ministry of Commerce
20 A & B Preah Norodom Boulevard
Phnom Penh 12205
Senior Minister's Cabinet
Tel: (855) 23 427 358/214 946
Fax: (855) 23-213-288/991-708

Downloaded from http://www.khmerlaws.com

# សំរេច

**ប្រការ ១:** ត្រូវបានកែសំរួលប្រកាសអន្តរក្រសួងលេខ ០៤៤ MOC/SM 2007 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការកែសំរួលការកំណត់កំរៃគ្រប់គ្រងការនាំចេញ (Export Management Fee) និង សោហ៊ុយពាក់ព័ន្ធត្រង់ប្រការ ២ ដោយប្តូរតម្លៃពី 0.02025 KHR/1,000 $M^2$ ទៅជា 0.02025 USD/1,000 $M^2$ សំរាប់គ្រប់ប្រភេទក្រណាត់ ។

**ប្រការ ២:** ត្រូវបានកែសំរួលប្រកាសអន្តរក្រសួងលេខ ០៤៤ MOC/SM 2007 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការកែសំរួលការកំណត់កំរៃគ្រប់គ្រងការនាំចេញ (Export Management Fee) និង សោហ៊ុយពាក់ព័ន្ធត្រង់ប្រការ ៣ ដោយបញ្ចុះកំរៃលើផលិតផលទោចក្រយានពី ៣.៥០០ រៀលក្នុងមួយគ្រឿងសំរាប់គ្រប់ទិសដៅនាំចេញទាំងអស់ទៅជា ៣៥០ រៀលក្នុងមួយគ្រឿង ។

**ប្រការ ៣:** ត្រូវបានកំណត់ការបង់កំរៃគ្រប់គ្រងការនាំចេញ (EMF) លើមុខទំនិញប៊ូឡុងដែលពុំទាន់បានកំណត់កំរៃកន្លងមក មានតំលៃស្មើនឹង ២.០០០ រៀលក្នុងមួយតោន សំរាប់គ្រប់ទិសដៅនាំចេញទាំងអស់ ។

**ប្រការ ៤:** ប្រកាសទាំងឡាយណាដែលផ្ទុយទៅនឹងសេចក្តីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥:** គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្មត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៦:** ប្រកាសនេះមានអនុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម្ម_ប្រសិទ្ធ

**ចម្លងជូន:**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ស ខេង
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់ខេត្ត-ក្រុង
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

Downloaded from http://www.khmerlaws.com